ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
លេខ : ២៣៦១ មស.សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈរបស់ក្រសួងមុខងារសាធារណៈ

## រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅរបស់ក្រសួងមុខងារសាធារណៈ
- អនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ
- បានឃើញលិខិតលេខ ១៨៤៦ មស.គករ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៦ របស់ក្រសួងមុខងារសាធារណៈ
- យោងតាមការចាំបាច់

## សម្រេច

**ប្រការ១.-**

បង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈរបស់ក្រសួងមុខងារសាធារណៈ ដូចខាងក្រោម៖

| | | | | |
|---|---|---|---|---|
| ១. | ឯកឧត្តម | **យូ ស៊ីនឡុង** | រដ្ឋលេខាធិការ | ប្រធាន |
| ២. | ឯកឧត្តម | **សុខ វិសាល** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៣. | លោកជំទាវ | **ហូ សុវណ្ណិភា** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៤. | ឯកឧត្តម | **អុល រ៉ូ** | អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ | អនុប្រធានអចិន្ត្រៃយ៍ |
| ៥. | ឯកឧត្តម | **ចាន់ វណ្ណី** | អគ្គាធិការនៃអគ្គាធិការដ្ឋាន | សមាជិក |
| ៦. | ឯកឧត្តម | **ស៊ុំ វិនទិ** | នាយករងនៃសាលាភូមិន្ទរដ្ឋបាល | សមាជិក |
| ៧. | លោក | **ហែម មគ្គផល** | អគ្គាធិការរងនៃអគ្គាធិការដ្ឋាន | សមាជិក |

| | | | | |
|---|---|---|---|---|
| ៨. | លោកស្រី | **ឆាយ គីមសុទ្ធី** | អគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ | សមាជិក |
| ៩. | លោក | **ឆាក់ ដាខ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ | សមាជិក |
| ១០. | លោក | **ឈុន សុជាតិ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានគ្រប់គ្រងមុខងារសាធារណៈ | សមាជិក |
| ១១. | លោក | **ស៊ិន់ សេរីវឌ្ឍនា** | អនុប្រធាននាយកដ្ឋានត្រួតពិនិត្យនិងវាយតម្លៃ នៃអគ្គនាយកដ្ឋានគោលនយោបាយមុខងារសាធារណៈ | សមាជិក |
| ១២. | លោក | **ណាន នីម** | អនុប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង | សមាជិក |
| ១៣. | លោក | **ឫទ្ធី សុគន្ធារិទ្ធិ** | ប្រធាននាយកដ្ឋានគ្រប់គ្រងបុគ្គលិក | មន្ត្រីបង្គោល |
| ១៤. | លោក | **ម៉េង ម៉ង់ទិត** | ប្រធាននាយកដ្ឋានរដ្ឋបាលនិងសរុប | មន្ត្រីបង្គោល |

**ប្រការ២.—**

ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈរបស់ក្រសួងមុខងារសាធារណៈ មានតួនាទីនិងភារកិច្ច ដូចខាងក្រោម៖

- ទទួលខុសត្រូវចំពោះមុខប្រធានស្ថាប័នក្នុងការគ្រប់គ្រង និង ដឹកនាំគ្រប់ការងារពាក់ព័ន្ធទៅនឹងកម្មវិធី យុទ្ធសាស្ត្រ និងសកម្មភាពកែទម្រង់រដ្ឋបាលសាធារណៈរបស់ក្រសួង
- សម្របសម្រួលការងារកែទម្រង់រដ្ឋបាលសាធារណៈ រវាងក្រសួងមុខងារសាធារណៈ និង មន្ទីរមុខងារសាធារណៈ រាជធានី ខេត្ត ជាមួយលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ
- សម្របសម្រួលនិងជំរុញការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងសកម្មភាពកែទម្រង់រដ្ឋបាលសាធារណៈ
- រៀបចំផែនការសកម្មភាពកែទម្រង់រដ្ឋបាលសាធារណៈក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ព្រមទាំងរៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពកែទម្រង់រដ្ឋបាលសាធារណៈប្រចាំឆមាសជូនប្រធានស្ថាប័ន និង លេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ។

**ប្រការ៣.—**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៤.—**

អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានគ្រប់គ្រងមុខងារសាធារណៈ អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយមុខងារសាធារណៈ អគ្គាធិការនៃអគ្គាធិការដ្ឋាន សាលាភូមិន្ទរដ្ឋបាល នាយកខុទ្ទកាល័យ អង្គភាពពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ ២០១៦

**ពេជ្រ ប៊ុនធិន**

**<u>កន្លែងទទួល៖</u>**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ "ដើម្បីជូនជ្រាប"
- មន្ទីរមុខងារសាធារណៈរាជធានី ខេត្ត "ដើម្បីសហការអនុវត្ត"
- ដូចប្រការ៤ "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ